(2443) (៥-២១)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ៧៥ ប្រក/ប.ដ.ស

# ប្រកាស

ស្តីពី

# ការគ្រប់គ្រងសហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់

* * * * *

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី [illegible] ស្តីពីលិខិតអនុញ្ញាតសាងសង់
- តាមការចាំបាច់របស់ក្រសួង : [illegible]

## សំរេច

អាសយដ្ឋាន : លេខ ៧៧១ - ៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុង ភ្នំពេញ
Tel : (855) 023 215 659 - 215 660 , Fax : (855) 023 215 277 , e-mail : im. c lim. @ Camnet. Com. Kh

ប្រការ ១.-

សហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ទាំងអស់ដែលធ្វើសកម្មភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ប្រការ ២.-

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ ត្រូវបានបែងចែកជាបួន ប្រភេទ :

ក-ប្រភេទទី១ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ក.១ ស្ថាបត្យករយ៉ាងតិច ៣ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ ឆ្នាំ ។

ក.២ វិស្វករយ៉ាងតិច ៥ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេង១ យ៉ាង តិច ៥ ឆ្នាំ ។

ក.៣ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុងសហគ្រាស និង ក្រុមហ៊ុន។

ក.៤ អ្នកបច្ចេកទេសថ្នាក់មធ្យមមួយចំនួនសមស្រប ។

ក.៥ បទពិសោធន៍លើការងារសិក្សាគំរោងដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃសិក្សាគំរោងយ៉ាងតិចចំនួន ៨០០.០០០.០០០ រៀល ។

ក.៦ ដើមទុនយ៉ាងតិចចំនួន ២០០.០០០.០០០រៀល ដែលទទួលស្គាល់ ដោយ ធនាគារស្របច្បាប់ ។

ខ-ប្រភេទទី២ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ខ.១ ស្ថាបត្យករយ៉ាងតិច ២ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

ខ.២ វិស្វករយ៉ាងតិច ៤នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេង១ យ៉ាងតិច ៤ ឆ្នាំ ។

ខ.៣ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១នាក់ ដែលមានបទពិសោធន៍លើការងារមុខជំនាញយ៉ាងតិច ៦ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ខ.៤ អ្នកបច្ចេកទេសថ្នាក់មធ្យមមួយចំនួនសមស្រប ។

ខ.៥ បទពិសោធន៍លើការងារសិក្សាគំរោង ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតំលៃសិក្សាគំរោងយ៉ាងតិចចំនួន ២០០.០០០.០០០រៀល ។

ខ.៦ ដើមទុនយ៉ាងតិចចំនួន ៨០.០០០.០០០រៀល ដែលទទួលស្គាល់ដោយ ធនាគារស្របច្បាប់ ។

គ-ប្រភេទទី៣ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

គ.១ ស្ថាបត្យករយ៉ាងតិច ២ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ឆ្នាំ ។

គ.២ វិស្វករយ៉ាងតិច ៣នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេង១យ៉ាងតិច ៣ឆ្នាំ ។

គ.៣ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុង សហគ្រាស និង ក្រុមហ៊ុន ។

គ.៤ អ្នកបច្ចេកទេសថ្នាក់មធ្យមមួយចំនួនសមស្រប ។

គ.៥ ដើមទុនយ៉ាងតិចចំនួន ២០.០០០.០០០ រៀល ដែលទទួលស្គាល់ដោយ ធនាគារស្របច្បាប់ ។

ឃ -ប្រភេទទី៤ : ជារូបវន្តបុគ្គល :

ឃ.១ ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ឆ្នាំដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល ។

ឃ.២ ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេង១ យ៉ាងតិច ៥ឆ្នាំ ។

ឃ.៣ ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ឆ្នាំ ។

ឃ.៤ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ឆ្នាំ។

ឃ.៥ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ ឆ្នាំ ។

ឃ.៦ វិស្វករស្ថិតនៅខេត្តក្រុង ដែលគ្មានស្ថាបត្យករ និង អ្នកបច្ចេកទេសសំណង់អគារ ឬ សំណង់ស៊ីវិល ។

ឃ.៧ អ្នកបច្ចេកទេសថ្នាក់មធ្យមសំណង់អគារ ឬ សំណង់ស៊ីវិលស្ថិតនៅខេត្ត ក្រុង ដែលគ្មានស្ថាបត្យករ និង វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ។

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ អាចសុំតម្លើងឋានៈរបស់ខ្លួនទៅពេលណាដែលសហគ្រាស និង ក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ ២នេះ និង មានលិខិតបញ្ជាក់ពីការបង់ពន្ធទៀងទាត់ជូនរដ្ឋ ។

## ប្រការ ៣.-

សហគ្រាស និង ក្រុមហ៊ុនសាងសង់ ត្រូវបានបែងចែកជាបួនប្រភេទ :

ក-ប្រភេទទី១ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ក.១ ចំនួនវិស្វករ ២នាក់ និង ស្ថាបត្យករ ២នាក់ មានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១០ឆ្នាំ នៅក្នុងនោះវិស្វករ ១នាក់ ទទួលបន្ទុកជានាយកបច្ចេកទេស និង ស្ថាបត្យករ ១នាក់ ជានាយកគំរោង ។

ក.២ វិស្វករយ៉ាងតិច ៦នាក់ ទទួលបន្ទុកជំនាញផ្សេង១ ( អគ្គិសនី មេកានិច ទឹក ក្លាក្លសាស្ត្រ ឋានលេខា )

ក.៣ ដើមទុនយ៉ាងតិចចំនួន ៤០០.០០០.០០០រៀល ដែលទទួលស្គាល់ដោយ ធនាគារស្របច្បាប់។

ក.៤ បទពិសោធន៍ការងារសាងសង់ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃយ៉ាងតិចចំនួន ២០.០០០.០០០.០០០រៀល ។

ខ-ប្រភេទទី២ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ខ.១ ចំនួនវិស្វករ ១នាក់ និង ស្ថាបត្យករ ១នាក់ មានបទពិសោធន៍ការងារក្នុងមុខជំនាញ យ៉ាងតិច ៨ឆ្នាំ នៅក្នុងនោះវិស្វករមានតួនាទីជានាយកបច្ចេកទេស និង ស្ថាបត្យករ ជានាយកគំរោង នៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ខ.២ វិស្វករយ៉ាងតិច ៤នាក់ ទទួលបន្ទុកជំនាញផ្សេងៗ ( អគ្គិសនី មេកានិច ទឹក ភូគព្ភសាស្ត្រ ហាង់លេខា )

ខ.៣ ដើមទុនយ៉ាងតិចចំនួន ១២០.០០០.០០០រៀល ដោយមានការទទួលស្គាល់ពីធនាគារស្របច្បាប់ ។

ខ.៤ បទពិសោធន៍លើការងារសាងសង់ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃយ៉ាងតិច ចំនួន ៤.០០០.០០០.០០០រៀល ។

គ-ប្រភេទទី៣ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

គ.១ ចំនួនវិស្វករ ១នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៃសហគ្រាស និង ក្រុមហ៊ុន ។

គ.២ វិស្វករ ២នាក់ ដែលទទួលបន្ទុកជំនាញផ្សេងៗ ។

គ.៣ ដើមទុនយ៉ាងតិច ២០.០០០.០០០រៀល ដោយមានការទទួលស្គាល់ពីធនាគារស្របច្បាប់ ។

ឃ-ប្រភេទទី៤ : ជាក្រុមជាងសំណង់ :

ឃ.១ មេជាងដែលមានស្នាដៃ និង បទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១០ឆ្នាំ ។

ឃ.២ ជាងសំណង់មួយចំនួនសមស្រប ។

សហគ្រាស និង ក្រុមហ៊ុនសាងសង់ អាចសុំតម្លើងឋានៈប្រភេទ របស់ខ្លួនទៅពេលណា ដែលសហគ្រាស និង ក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ ៣នេះ និង មានលិខិតបញ្ជាក់ពីការបង់ពន្ធទៀងទាត់ជូនរដ្ឋ ។

## ប្រការ ៤.-

អាជ្ញាធរដែលមានសមត្ថកិច្ចបើក បិទ ផ្អាក តាមដាន និង ត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងប្លង់ និងសាងសង់ មាន :

១-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់
- ប្រកាសបិទ ផ្អាកអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់
- តាមដាន ត្រួតពិនិត្យគ្រប់សកម្មភាពអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ។

២-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង

- ទទួលបន្ទុកសំរបសំរួល ដើម្បីលើកសំណើជូនក្រសួងធ្វើសេចក្តីសំរេចក្នុងការចេញលិខិតអនុញ្ញាត បើក បិទ ផ្អាក ការប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់របស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់

- តាមដាន ត្រួតពិនិត្យសកម្មភាពរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់នៅក្នុងមូលដ្ឋានរបស់ខ្លួន និងរាយការណ៍ជូនក្រសួងដើម្បីពិនិត្យដោះស្រាយ ។

## ប្រការ ៥ .-

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ទាំងអស់ ដែលមានបំណងធ្វើអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្ម នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

រូបវន្តបុគ្គល ( ឃ៦-ឃ៧ ) និង ក្រុមជាងសំណង់ ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្មទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ។

## ប្រការ ៦ .-

ចំពោះ :

១- សហគ្រាស និង ក្រុមហ៊ុនដែលមានលិខិតអនុញ្ញាតពីស្ថាប័នផ្សេងៗកន្លងមក ត្រូវដាក់ពាក្យសុំប្តូរយកលិខិតអនុញ្ញាតថ្មីពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

២- រូបវន្តបុគ្គល ( ឃ៦-ឃ៧ ) និង ក្រុមជាងសំណង់ ដែលមានលិខិតអនុញ្ញាតពីស្ថាប័នផ្សេងៗកន្លងមក ត្រូវដាក់ពាក្យសុំប្តូរយកលិខិតអនុញ្ញាតថ្មីពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ។

## ប្រការ ៧.-

ទម្រង់បែបបទសុំប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ត្រូវមានល័ក្ខខណ្ឌដូចតទៅ :

១- ប្រធានសហគ្រាស និង ក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរ ។

២- ប្រធានសហគ្រាស និង ក្រុមហ៊ុនត្រូវមកដាក់ពាក្យសុំដោយខ្លួនឯងផ្ទាល់ ។

៣- នាយកបច្ចេកទេសនៃសហគ្រាស និង ក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរ ។

៤- សំណុំឯកសារដែលត្រូវបំពេញរួមមាន :

- ពាក្យសុំប្រកបអាជីវកម្ម
- ជីវប្រវត្តិសង្ខេបរបស់ប្រធានសហគ្រាស និង ក្រុមហ៊ុន ដោយមានបិទរូបថតទំហំ ៤ x ៦

- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណរបស់ប្រធានសហគ្រាស និង ក្រុមហ៊ុនដែលមានធ្វើទីត្យានុកូលកម្មនៅសាលា ខេត្ត ក្រុង ២ ច្បាប់
- លិខិតថ្កោលទោសរបស់ប្រធានសហគ្រាស និង ក្រុមហ៊ុន ( ច្បាប់ដើម ) ១ ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់នាយកបច្ចេកទេសដោយមានបិទរូបថតទំហំ ៤ x ៦ ៤ ច្បាប់
- លក្ខន្តិកៈរបស់សហគ្រាស និង ក្រុមហ៊ុន ៤ ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាសនិងក្រុមហ៊ុន និងអាជ្ញាធរសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម ៤ ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាសនិងក្រុមហ៊ុនៈ និងវិស្វករដែលជានាយកបច្ចេកទេស ៤ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្ររបស់អ្នកបច្ចេកទេសដែលមានធ្វើទីត្យានុកូលកម្មនៅសាលាខេត្ត ក្រុង ៤ ច្បាប់
- បញ្ជីរាយឈ្មោះអ្នកបច្ចេកទេស និង អង្គការលេខរបស់សហគ្រាស និង ក្រុះហ៊ុន ៤ ច្បាប់
- ឯកសារស្នាដៃ ៤ ច្បាប់
- បញ្ជីសម្ភារៈ បរិក្ខារសិក្សាគំរោងប្លង់ ( *សំរាប់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់* ) ២ ច្បាប់
- បញ្ជីសម្ភារៈ បរិក្ខារគ្រឿងសំណង់ ( *សំរាប់សហគ្រាស និង ក្រុមហ៊ុនសាងសង់* ) ៤ ច្បាប់
- ឯកសារធនាគារ ២ ច្បាប់
- បង្កាន់ដៃបង់ពន្ធអាករ ( ច្បាប់ដើម ) ៤ ច្បាប់
- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ១ ច្បាប់

១ ច្បាប់

## ប្រការ ៨.-

រាល់សហគ្រាស និង ក្រុមហ៊ុនបរទេសដែលមានបំណងប្រកបអាជីវកម្មសិក្សាគំរោងប្លង់ ឬ ផ្តល់យោបល់ ពិគ្រោះបច្ចេកទេស និងសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

រាល់សហគ្រាស និង ក្រុមហ៊ុនបរទេសដែលកំពុងប្រកបអាជីវកម្មសិក្សាគំរោងប្លង់ឬ ផ្តល់យោបល់ពិគ្រោះបច្ចេកទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីមានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងហើយក៏ដោយ ក៏ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ដែរ ។

## ប្រការ ៩.-

រាល់ការចុះបញ្ជី ការចេញលិខិតអនុញ្ញាត សហគ្រាសនិងក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ រូបវន្តបុគ្គល និង ក្រុមជាងសំណង់ ត្រូវបង់ពន្ធអាករផ្សេងៗ ស្របតាមការកំណត់នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ប្រការ ១០.-

លិខិតអនុញ្ញាតប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់មានសុពលភាពរយៈពេល ៣ឆ្នាំគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ។ ៗ

រយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាព សហគ្រាស និង ក្រុមហ៊ុន ធ្វើអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាជាថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ក្នុងករណីសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម សហគ្រាស និង ក្រុមហ៊ុនត្រូវធ្វើពាក្យសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតចាស់ និង បង្កាន់ដៃបង់ពន្ធអាករថ្មី ។

ក្នុងករណីសុំតម្លើងឋានៈប្រភេទ សហគ្រាស និង ក្រុមហ៊ុនត្រូវធ្វើបែបបទស្នើសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យ សំរេច ។

សហគ្រាស និង ក្រុមហ៊ុនត្រូវតំកល់ទុករបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រាល់ដំណាច់ឆ្នាំទីមួយ ១ ។

## ប្រការ ១១.-

ត្រូវប្រកាសផ្អាក ឬ បិទ ចំពោះសហគ្រាស ឬ ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ទាំងឡាយណាដែលប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ដោយគ្មានលិខិតអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

## ប្រការ ១២ .-

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកសំណង់ អគ្គនាយករៀបចំដែនដីនិងនគរូបនីយកម្ម អគ្គនាយកសុរិយោដីនិងភូមិសាស្ត្រ អធិការ និង ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន ។

## ប្រការ ១៣.-

ប្រកាសនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ១៩៩៩

អ៊ឹម ឈុនលឹម

ចម្លងជូន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ១២
- ឯកសារ-កាលប្បវត្តិ